**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
**គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍**
**រាជធានីភ្នំពេញ**

# បទបង្ហាញស្តីពី

## ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍៖ បទពិសោធន៍ការប្រើប្រាស់ហិរញ្ញប្បទានក្នុងស្រុក (ថវិកាជាតិ) នៃរាជធានីភ្នំពេញ

ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ បង្ហាញដោយ **លោកវេជ្ជបណ្ឌិត ឡុង ឡាវី** អនុប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានីភ្នំពេញ និងជាអនុប្រធានអចិន្ត្រៃយ៍លេខាធិការដ្ឋានអេដស៍រាជធានីភ្នំពេញ

## មាតិកានៃបទបង្ហាញ


1. ស្ថានភាពទូទៅ និងប្រជាសាស្ត្រនៅរាជធានីភ្នំពេញ
2. សាវតា FTCI
3. ការរៀបចំយន្តការឆ្លើយតបនឹងមេរោគអេដស៍
4. លទ្ធផលអនុវត្តឆ្លើយតបនឹងមេរោគអេដស៍ ជំងឺអេដស៍នៅរាជធានីភ្នំពេញ មកដល់ត្រីមាសទី៣ ឆ្នាំ២០២៤
5. បទពិសោធន៍ការប្រើប្រាស់ថវិកាជាតិ ៨០,០០០,០០០រៀល
6. បញ្ហាប្រឈម
7. ទិសដៅបន្ត
8. សំណូមពរ

# ១-ស្ថានភាពទូទៅ និងប្រជាសាស្ត្រនៅរាជធានីភ្នំពេញ






| | |
|---|---|
| ផ្ទៃដីសរុប | =៦៩៥. ២១៨ គម² |
| ប្រជាជន | =២.២៨១.៩៥១ នាក់ |
| ចំនួនស្រីសរុប | =១.១៧៦.២៧៨ នាក |
| ចំនួនគ្រួសារ | = ៤៩៩.២៩៩ |
| ដង់ស៊ីតេ | = ៣.២៩៥នាក់/ គម² |
| ខណ្ឌ | =១៤ |
| សង្កាត់ | =១០៥ |
| ភូមិ | =៩៥៣ |

**+រចនាសម្ព័ន្ធមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ**

- ការិយាល័យជំនាញ ចំនួន ៤
- ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ចំនួន ៧
- មន្ទីរពេទ្យបង្អែក ចំនួន ៨
- មណ្ឌលសុខភាព ចំនួន ៤៦

**+សេវាថែទាំព្យាបាលអ្នកជំងឺអេដស៍ មានចំនួន ១៤ទីតាំង រួមមានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។**

- កន្លែងគ្រឹះស្ថានកំសាន្តសប្បាយ (ខារ៉ាអូខេ ម៉ាស្សា ភោជនីយដ្ឋានរាត្រី ក្រឹបកម្សាន្ត កាស៊ីណូ...) ១,៥៥២ កន្លែង
- បុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ (EW) ១៨,៩៩៨នាក់ (ស្រី ១៨៩៩៨នាក់)

- ក្រុមបុរសរួមភេទជាមួយបុរស (MSM) ១៣,៦៨៣នាក់
- ក្រុមបំលែងភេទ (TG) ៥,៩៣៥នាក់
- អ្នកប្រើគ្រឿងញៀន (PWID / PWUD) ៩៥៧នាក់ (ស្រី ១៦៣នាក់)
- អ្នកផ្ទុកមេរោគអេដស៍ដែលកំពុងទទួលការព្យាបាល (ART) ២៤,៧៩៩នាក់ (ស្រី ១០,១០០នាក់)
- អ្នកផ្ទុកមេរោគអេដស៍ដែលកំពុងទទួលការព្យាបាល (ART) មាន Viral Load Suppression ២១,០៧៨នាក់ (ស្រី ៩,៧៨២នាក់)

*__សាវតា__

## ផែនការយុទ្ធសាស្ត្រពន្លឿនការបញ្ចប់ការរាលដាលមេរោគអេដស៍ ជំងឺអេដស៍ នៅរាជធានីភ្នំពេញ

គំនិតផ្តួចផ្តើម Fast-Track Cities គឺជាភាពដៃគូសកលរវាងបណ្តាទីក្រុង/រាជធានីនៅជុំវិញពិភពលោក និងដៃគូស្នូលចំនួនបួន រួមមាន៖ សមាគមអ្នកផ្តល់សេវាថែទាំជំងឺអេដស៍អន្តរជាតិ (IAPAC) កម្មវិធីសហប្រជាជាតិរួមគ្នាស្តីពីមេរោគអេដស៍ ជំងឺអេដស៍ (UNAIDS) អង្គការសហប្រជាជាតិសម្រាប់លំនៅដ្ឋានមនុស្សជាតិ (UN-Habitat) និងទីក្រុងប៉ារីស(ប្រទេសបារាំង)។ គំនិតផ្តួចផ្តើមនេះត្រូវបានដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ២០១៤ នៅពេលដែលអភិបាលក្រុងមកពី

ទីក្រុងចំនួន២៦ ក្នុងពិភពលោក បានជួបជុំគ្នា និងអនុម័តសេចក្ដីប្រកាសទីក្រុងប៉ារីស ស្ដីពីការពន្លឿនការបញ្ចប់ការរីករាលដាលមេរោគអេដស៍នៅតាមទីក្រុង (សេចក្ដីថ្លែងការណ៍ទីក្រុងប៉ារីស)។ ចាប់តាំងពីពេលនោះមកបណ្ដារាជធានី និងទីក្រុងប្រមាណជាង ៣០០ បានអនុម័តលើសេចក្ដីប្រកាសនេះ។ សេចក្ដីថ្លែងការទីក្រុងប៉ារីស មានគោលបំណងពង្រឹងទីក្រុងនានាឱ្យសម្រេចបាននូវគោលដៅពន្លឿនសំខាន់ៗ ដើម្បីដោះស្រាយបញ្ហាវិសមភាពក្នុងការទទួលបានសេវាសុខភាព និងសង្គម និងគោលដៅសកលក្នុងការបញ្ចប់ការរីករាលដាលមេរោគអេដស៍នៅឆ្នាំ២០៣០។

នៅពេលដែលអភិបាលក្រុង ឬរដ្ឋបាលរាជធានី ចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍នេះ ទីក្រុងនឹងក្លាយជាសមាជិកនៃ "Fast-Track Cities"។ សេចក្ដីថ្លែងការណ៍គូសបញ្ជាក់នូវការប្ដេជ្ញាចិត្តមួយចំនួនដើម្បីសម្រេចបានវត្ថុបំណងរបស់គំនិតផ្ដួចផ្ដើមនេះ ហើយសេចក្ដីថ្លែងការណ៍ត្រូវបានធ្វើបច្ចុប្បន្នភាពកាលពីឆ្នាំ២០១៩។ គោលដៅសំខាន់គឺផ្ដើមចេញពីគន្លងឆ្ពោះទៅរកការបញ្ចប់ករណីឆ្លងថ្មី គ្មានការរើសអើង និងគ្មានការស្លាប់ដែលទាក់ទងនឹងជំងឺអេដស៍។ តាមរយៈការចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍នេះ អភិបាលក្រុង ឬរដ្ឋបាលរាជធានី ប្ដេជ្ញាថាទីក្រុងរបស់ពួកគេនឹង៖

១. បញ្ចប់ការរីករាលដាលមេរោគអេដស៍នៅក្នុងទីក្រុង និង រាជធានីនៅឆ្នាំ២០៣០

២. ផ្តោតការគិតគូរអំពីមនុស្សនៅគ្រប់សកម្មភាពអន្តរាគមន៍របស់ខ្លួន

៣. ដោះស្រាយឫសគល់នៃហានិភ័យ ភាពងាយរងគ្រោះ និងកត្តាចម្លងមេរោគអេដស៍

៤. ប្រើប្រាស់ការឆ្លើយតបទៅនឹងមេរោគអេដស៍សម្រាប់ការផ្លាស់ប្តូរសង្គមជាវិជ្ជមាន

៥. ផ្អែកតាមតម្រូវការមូលដ្ឋានជាក់ស្តែងកសាង និងពន្លឿនការឆ្លើយតបសមស្របទៅនឹងមេរោគអេដស៍

៦. កៀរគរធនធានដើម្បីផ្តល់សេវាសុខភាពសាធារណៈ និងការអភិវឌ្ឍប្រកបដោយចីរភាពរួមបញ្ចូលគ្នា

៧. រួបរួមគ្នាជាអ្នកដឹកនាំ។

## របាយការណ៍ឆ្លុះបញ្ចាំង
## សកម្មភាពស្តីពីការពន្លឿនការបញ្ចប់ការរាលដាល
## មេរោគអេដស៍ ជំងឺអេដស៍ នៅរាជធានីភ្នំពេញ ឆ្នាំ២០២៤

-បានរៀបចំផែនការយុទ្ធសាស្ត្រពន្លឿនការបញ្ចប់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍នៅរាជធានីភ្នំពេញ សម្រាប់ឆ្នាំ២០២២-២០២៥ ។

-បានរៀបចំរបាយការណ៍ឆ្លុះបញ្ចាំង អំពីការអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ នៅរាជធានីភ្នំពេញ រយៈពេល ៩ខែ ឆ្នាំ២០២៤ (Fast Track Cities)។

-បានកែសម្រួលរចនាសម្ព័ន្ធគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ។

-លទ្ធផលនៃការរៀបចំបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមបណ្ដាសង្កាត់ទទួលបាន១៤ខណ្ឌ លើ១៤ខណ្ឌ ស្មើនឹង ១០៥សង្កាត់។

-បានរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ផែនការ FTCI ឆ្នាំ២០២៤ និងអនុវត្តសកម្មភាពឆ្លើយតបមេរោគអេដស៍ ចំណាយបាន ៦២.៥% នៅសល់ពីរសកម្មភាពទៀត។

-បានសហការជាមួយ NAA និងគម្រោង LHSS ដើម្បីរៀបចំវគ្គបណ្ដុះបណ្ដាល ដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍តាមបណ្ដាសង្កាត់ ស្ដីពីតួនាទី ភារកិច្ចក្នុងការចូលរួមទប់ស្កាត់ការរាលដាលមេរោគអេដស៍ ជំងឺអេដស៍ ក្នុងមូលដ្ឋានរបស់ខ្លួន និងវគ្គបណ្ដុះបណ្ដាល ការធ្វើផែនការសកម្មភាព និងថវិកាបញ្ចូលក្នុងផែនការអភិវឌ្ឍន៍សង្កាត់ ស្ដីពីមេរោគអេដស៍ ជំងឺអេដស៍ សម្រាប់ឆ្នាំ២០២៥ខាងមុខ។

-គ្រោងរៀបចំប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៤។

-ការអនុវត្ត ស.ជ.ណ ២១៣ បានដំណើរការចុះឈ្មោះអ្នកជំងឺអេដស៍ទទួលបានបណ្ណសមធម៌ជាបណ្តើរៗ ដែលបានដំណើរការពីខែមករា ឆ្នាំ២០២៣។

១.ការឆ្លើយតបទៅនឹងគោលដៅ ៩៥បីដង គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញសម្រេចបាន៖

❖ **ទិដ្ឋភាពរួម**

**តារាងគោលដៅបញ្ចប់អេដស៍ ៩៥បីដង ក្នុងឆ្នាំ២០២៥**

(លទ្ធផលសម្រេចបានឆ្នាំ២០២៣-២០២៤)

| **ការផ្តល់សេវាដល់ប្រជាជនទូទៅក្នុងរាជធានីភ្នំពេញ** | **ការផ្តល់សេវាចំពោះប្រជាជនដែលមានទីលំនៅក្នុងរាជធានីភ្នំពេញ តាម UNAIDS** |
|---|---|
| ៩៥ ទី១ ទទួលបាន ១២០% | ៩៥ ទី១ ទទួលបាន ៩០% |
| ៩៥ ទី២ ទទួលបាន ១០០% | ៩៥ ទី២ ទទួលបាន ១០០% |
| ៩៥ ទី៣ ទទួលបាន ៩៨% | ៩៥ ទី៣ ទទួលបាន ៩៨% |

-ការរកឃើញករណីថ្មី នៃមេរោគអេដស៍ក្នុងរយៈពេលមួយឆ្នាំ ២០២៣

| | **Q1-2023** | **Q2-2023** | **Q3-2023** | **Q4-2023** | **Total** |
|---|---|---|---|---|---|
| ◆ ចំនួនធ្វើតេស្តក្នុងឆ្នាំ២០២៣ | | | | | **80273** |
| ◆ **Reactive** ប្រតិកម្ម | 515 | 535 | 607 | 500 | **2157** |

| | | | | | |
|---|---|---|---|---|---|
| ◆ **Confirm** ធ្វើតេស្តបញ្ជាក់ | 512 | 530 | 598 | 497 | **2137** |
| ◆ **Positive** វិជ្ជមាន | 508 | 528 | 594 | 489 | **2119** |
| ◆ **Enrolled ART** ចុះឈ្មោះទទួលសេវាព្យាបាល | 507 | 513 | 576 | 480 | **2076** |

-ការរកឃើញករណីថ្មី នៃមេរោគអេដស៍ក្នុងរយៈពេល ៩ខែ ឆ្នាំ២០២៤ (ផែនការ២០២៤)

| | **Q1-2024** | **Q2-2024** | **Q3-2024** | **Q4-2024** | **Total** |
|---|---|---|---|---|---|
| ◆ **ចំនួនធ្វើតេស្តក្នុងឆ្នាំ២០២៤** | | | | | **74856** |
| ◆ **Reactive** ប្រតិកម្ម | 510 | 515 | 554 | | |
| ◆ **Confirm** ធ្វើតេស្តបញ្ជាក់ | 504 | 506 | 548 | | |
| ◆ **Positive** វិជ្ជមាន | 494 | 503 | 546 | | |
| ◆ **Enrolled ART** ចុះឈ្មោះទទួលសេវាព្យាបាល | 481 | 493 | 529 | | |

# បទពិសោធន៍នៃការប្រើប្រាស់ថវិកាជាតិ ៨០,០០០,០០០រៀល របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ ផែនការសកម្មភាព និងថវិកា ឆ្នាំ២០២៤

| ២.១.២.១ | សកម្មភាពទី១ គាំទ្រដល់ផែនការសកម្មភាព ប្រយុទ្ធនឹងមេរោគអេដស៍និង ជម្ងឺអេដស៍ របស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ភ្នំពេញ | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២.១.២.១.១ សកម្មភាពរងទី១៖ សិក្ខាសាលា ផ្សព្វផ្សាយ | | | | | | | | |
| **Activity:** | **1-សិក្ខាសាលាគណៈកម្មាធិការប្រយុទ្ធនឹងជម្ងឺអេដស៍រាជធានីភ្នំពេញ** | | | | | | | |
| ល.រ | អធិប្បាយ ជាខ្មែរ | អធិប្បាយ ជា | ឯកត្តាវាស់ | តម្លៃរាយ (៛) | ចំនួន មនុស្ស | ចំនួន ម៉ោង/ថ្ងៃ | ចំនួន ដង/១ឆ្នាំ | សរុប (៛) |
| | | | | | | | | **9,296,000.00** |
| 1 | គ្រូឧទ្ទេស | | នាក់/ថ្ងៃ | 80,000 | 1 | 8 | 2 | 1,280,000.00 |
| 2 | អ្នកសំរបសំរួល | | នាក់/វគ្គ | 40,000 | 1 | 1 | 2 | 80,000.00 |
| 3 | អ្នកជំនួយការ | | នាក់/វគ្គ | 20,000 | 1 | 1 | 2 | 40,000.00 |
| 4 | អ្នកចូលរួម | | នាក់/វគ្គ | | 61 | 1 | 2 | - |
| 5 | ឯកសារ និង សម្ភារៈ | | សន្លឹក | 20,000 | 61 | 1 | 2 | 2,440,000.00 |
| 6 | រៀបចំទីតាំង និង អាហារសម្រន់ | | | 40,000 | 64 | 1 | 2 | 5,120,000.00 |
| 7 | ម៉ាស | | រួម | 10,000 | 4 | 1 | 2 | 80,000.00 |
| 8 | អាល់កុល | | រួម | 2,000 | 64 | 1 | 2 | 256,000.00 |
| **Activity:** | **2-សិក្ខាសាលាលេខាធិការដ្ឋានប្រយុទ្ធនឹងជម្ងឺអេដស៍រាជធានីភ្នំពេញ** | | | | | | | |
| ល.រ | អធិប្បាយ ជាខ្មែរ | អធិប្បាយ ជា អង់គ្លេស | ឯកត្តាវាស់ | តម្លៃរាយ (៛) | ចំនួន មនុស្ស | ចំនួន ម៉ោង/ថ្ងៃ | ចំនួន ដង/១ឆ្នាំ | សរុប (៛) |
| | | | | | | | | **4,586,000.00** |
| 1 | គ្រូឧទ្ទេស | | នាក់/ថ្ងៃ | 80,000 | 1 | 8 | 1 | 640,000.00 |
| 2 | អ្នកសំរបសំរួល | | នាក់/វគ្គ | 40,000 | 1 | 1 | 1 | 40,000.00 |
| 3 | អ្នកជំនួយការ | | នាក់/វគ្គ | 20,000 | 1 | 1 | 1 | 20,000.00 |
| 4 | អ្នកចូលរួម | | នាក់/វគ្គ | | 60 | 1 | 1 | - |
| 5 | ឯកសារ និង សម្ភារៈ | | សន្លឹក | 20,000 | 60 | 1 | 1 | 1,200,000.00 |
| 6 | រៀបចំទីតាំង និង អាហារសម្រន់ | | | 40,000 | 63 | 1 | 1 | 2,520,000.00 |
| 7 | ម៉ាស | | រួម | 10,000 | 4 | 1 | 1 | 40,000.00 |
| 8 | អាល់កុល | | រួម | 2,000 | 63 | 1 | 1 | 126,000.00 |
| **Activity:** | **3-សិក្ខាសាលាផ្សព្វផ្សាយពីការបង្ការការឆ្លងមេរោគអេដស៍ និងការបង្កបរិយាកាសគាំទ្រ ដល់ម្ចាស់សេវាកំសាន្តសប្បាយ** | | | | | | | - |
| ល.រ | អធិប្បាយ ជាខ្មែរ | អធិប្បាយ ជា អង់គ្លេស | ឯកត្តាវាស់ | តម្លៃរាយ (៛) | ចំនួន មនុស្ស | ចំនួន ម៉ោង/ថ្ងៃ | ចំនួន ដង/១ឆ្នាំ | សរុប (៛) |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | **9,172,000.00** |
| 1 | គ្រូឧទ្ទេស | | នាក់/ថ្ងៃ | 80,000 | 1 | 8 | 2 | 1,280,000.00 |
| 2 | អ្នកសំរបសំរួល | | នាក់/វគ្គ | 40,000 | 1 | 1 | 2 | 80,000.00 |
| 3 | អ្នកជំនួយការ | | នាក់/វគ្គ | 20,000 | 1 | 1 | 2 | 40,000.00 |
| 4 | អ្នកចូលរួម | | នាក់/វគ្គ | | 60 | 1 | 2 | - |
| 5 | ឯកសារ និង សម្ភារៈ | | សន្លឹក | 20,000 | 60 | 1 | 2 | 2,400,000.00 |
| 6 | រៀបចំទីតាំង និង អាហារសម្រន់ | | | 40,000 | 63 | 1 | 2 | 5,040,000.00 |
| 7 | ម៉ាស | | រួម | 10,000 | 4 | 1 | 2 | 80,000.00 |
| 8 | អាល់កុល | | រួម | 2,000 | 63 | 1 | 2 | 252,000.00 |
| **Activity:** | **4-សិក្ខាសាលាសម្របសម្រួលជាមួយអង្គការជាដៃគូរដែលបានអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងមេរោគអេដស៍នៅរាជធានីភ្នំពេញ** | | | | | | | - |
| ល.រ | អធិប្បាយ ជាខ្មែរ | អធិប្បាយ ជា | ឯកត្តាវាស់ | តម្លៃរាយ (៛) | ចំនួន មនុស្ស | ចំនួន ម៉ោង/ថ្ងៃ | ចំនួន ដង/១ឆ្នាំ | សរុប (៛) |
| | | | | | | | | **6,748,000.00** |
| 1 | គ្រូឧទ្ទេស | | នាក់/ថ្ងៃ | 80,000 | 1 | 8 | 2 | 1,280,000.00 |
| 2 | អ្នកសំរបសំរួល | | នាក់/វគ្គ | 40,000 | 1 | 1 | 2 | 80,000.00 |
| 3 | អ្នកជំនួយការ | | នាក់/វគ្គ | 20,000 | 1 | 1 | 2 | 40,000.00 |
| 4 | អ្នកចូលរួម | | នាក់/វគ្គ | | 41 | 1 | 2 | - |
| 5 | ឯកសារ និង សម្ភារៈ | | សន្លឹក | 20,000 | 41 | 1 | 2 | 1,640,000.00 |
| 6 | រៀបចំទីតាំង និង អាហារសម្រន់ | | | 40,000 | 44 | 1 | 2 | 3,520,000.00 |
| 7 | ម៉ាស | | រួម | 10,000 | 2 | 1 | 2 | 40,000.00 |
| 8 | អាល់កុល | | រួម | 2,000 | 37 | 1 | 2 | 148,000.00 |
| **Activity:** | **5- ទិវាពិភពលោកប្រយុទ្ធនឹងជម្ងឺអេដស៍ដើម្បីលើកកម្ពស់ការយល់ដឹងនិងកាត់បន្ថយការរើសអើងចំពោះអ្នករស់នៅមេរោគអេដស៍និងប្រជាជនគន្លឹះ** | | | | | | | |
| ល.រ | អធិប្បាយ ជាខ្មែរ | អធិប្បាយ ជា | ឯកត្តាវាស់ | តម្លៃរាយ (៛) | ចំនួន មនុស្ស | ចំនួនថ្ងៃ | ចំនួន ដង/១ឆ្នាំ | សរុប (៛) |
| | | | | | | | | **26,090,000.00** |
| 1- | ទីកន្លែង និង អាហារសម្រន់ | | នាក់ | 40,000 | 400 | 1 | 1 | 16,000,000.00 |
| 2- | ថតចម្លងឯកសារ និង សម្ភារៈ | | នាក់ | 20,000 | 400 | 1 | 1 | 8,000,000.00 |
| 3- | ប្រាក់ឧបត្ថម្ភសម្រាប់គ្រូឧទ្ទេស | | នាក់ | 640,000 | 1 | 1 | 1 | 640,000.00 |
| 4- | អ្នកសម្របសម្រួល | | នាក់ | 40,000 | 8 | 1 | 1 | 320,000.00 |
| 5- | ជំនួយការអ្នកសម្រសម្រួល | | នាក់ | 20,000 | 8 | 1 | 1 | 160,000.00 |
| 6- | ម៉ាស់ | | រួម | 10,000 | 17 | 1 | 1 | 170,000.00 |
| 7- | អាល់កុល | | រួម | 2,000 | 400 | 1 | 1 | 800,000.00 |

២.១.២.១. ២ សកម្មភាពរងទី២៖ ការបណ្តុះបណ្តាល

**Activity:** 1- វគ្គបណ្តុះបណ្តាលស្តីពីសមាហរណកម្ម កម្មវិធីអេដស៍ក្នុងផែនការអភិវឌ្ឍន៍សង្កាត់

| ល.រ | អធិប្បាយ ជាខ្មែរ | អធិប្បាយ ជា អង់គ្លេស | ឯកត្តាវាស់ | តម្លៃរាយ (៛) | ចំនួន មនុស្ស | ចំនួន ម៉ោង/ថ្ងៃ | ចំនួន ដង/១ឆ្នាំ | សរុប (៛) |
|---|---|---|---|---|---|---|---|---|
| | | | | | | | | **24,108,000.00** |
| 1 | គ្រូឧទ្ទេស | | នាក់/ថ្ងៃ | 80,000 | 1 | 16 | 3 | 3,840,000.00 |
| 2 | អ្នកសំរបសំរួល | | នាក់/វគ្គ | 40,000 | 1 | 2 | 3 | 240,000.00 |
| 3 | អ្នកជំនួយការ | | នាក់/វគ្គ | 20,000 | 1 | 2 | 3 | 120,000.00 |
| 4 | អ្នកចូលរួម | | នាក់/វគ្គ | | 51 | 2 | 3 | - |
| 5 | ឯកសារ និង សម្ភារៈ | | សន្លឹក | 20,000 | 51 | 2 | 3 | 6,120,000.00 |
| 6 | រៀបចំទីតាំង និង អាហារសម្រន់ | | | 40,000 | 54 | 2 | 3 | 12,960,000.00 |
| 7 | ម៉ាស | | រួម | 10,000 | 3 | 2 | 3 | 180,000.00 |
| 8 | អាល់កុល | | រួម | 2,000 | 54 | 2 | 3 | 648,000.00 |
| | | | | | | | | **80,000,000.00** |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ

## តារាងគម្រោងចំណាយ

## ផែនការអនុវត្តគម្រោង ទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍និង ជម្ងឺអេដស៍ ឆ្នាំ ២០២៤

| ល.រ | បរិយាយសកម្មភាព | ចំនួនថវិកាស្នើសុំ (រៀល) | កាលបរិច្ឆេទសកម្មភាពដែលគ្រោងអនុវត្តន៍ | ផ្សេងៗ |
|---|---|---|---|---|
| ១ | សិក្ខាសាលាលេខាធិការដ្ឋានប្រយុទ្ធនឹងជម្ងឺអេដស៍រាជធានីភ្នំពេញ | 4,586,000.00 | ខែ មីនា ឆ្នាំ ២០២៤ | |
| ២ | សិក្ខាសាលាសម្របសម្រួលជាមួយអង្គការដៃគូដែលបានអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងមេរោគអេដស៍នៅរាជធានីភ្នំពេញ | 3,374,000.00 | ខែ មីនា ឆ្នាំ ២០២៤ | |
| ៣ | សិក្ខាសាលាផ្សព្វផ្សាយពីការបង្ការការឆ្លងមេរោគអេដស៍ និងការបង្ករ បរិយាកាសគាំទ្រ ដល់ម្ចាស់សេវាកំសាន្តសប្បាយ | 4,586,000.00 | ខែ ឧសភា ឆ្នាំ ២០២៤ | |
| ៤ | សិក្ខាសាលាផ្សព្វផ្សាយពីការបង្ការការឆ្លងមេរោគអេដស៍ និងការបង្ករ បរិយាកាសគាំទ្រ ដល់ម្ចាស់សេវាកំសាន្តសប្បាយ | 4,586,000.00 | ខែឧសភា ឆ្នាំ ២០២៤ | |
| ៥ | វគ្គបណ្តុះបណ្តាលស្តីពីសមាហរណកម្ម កម្មវិធីអេដស៍ ក្នុង ផែនការអភិវឌ្ឍន៍សង្កាត់ | 8,036,000.00 | ខែ មិថុនា ឆ្នាំ ២០២៤ | |
| ៦ | វគ្គបណ្តុះបណ្តាលស្តីពីសមាហរណកម្ម កម្មវិធីអេដស៍ ក្នុង ផែនការអភិវឌ្ឍន៍សង្កាត់ | 8,036,000.00 | ខែ មិថុនា ឆ្នាំ ២០២៤ | |
| ៧ | វគ្គបណ្តុះបណ្តាលស្តីពីសមាហរណកម្ម កម្មវិធីអេដស៍ ក្នុង ផែនការអភិវឌ្ឍន៍សង្កាត់ | 8,036,000.00 | ខែ មិថុនា ឆ្នាំ ២០២៤ | |
| ៨ | សិក្ខាសាលាគណៈកម្មាធិការប្រយុទ្ធនឹងជម្ងឺអេដស៍រាជធានីភ្នំពេញ | 4,648,000.00 | ខែ កក្កដា ឆ្នាំ ២០២៤ | |
| ៩ | សិក្ខាសាលាសម្របសម្រួលជាមួយអង្គការដៃគូដែលបានអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងមេរោគអេដស៍នៅរាជធានីភ្នំពេញ | 3,374,000.00 | ខែ តុលា ឆ្នាំ ២០២៤ | |
| ១០ | សិក្ខាសាលាគណៈកម្មាធិការប្រយុទ្ធនឹងជម្ងឺអេដស៍រាជធានីភ្នំពេញ | 4,648,000.00 | ខែ វិច្ឆិកា ឆ្នាំ ២០២៤ | |
| ១១ | ទិវាពិភពលោកប្រយុទ្ធនឹងជម្ងឺអេដស៍ដើម្បីលើកកំពស់ ការយល់ដឹង និង កាត់បន្ថយការរើសអើង ចំពោះអ្នករស់នៅជាមួយមេរោគអេដស៍ និង ប្រជាជនគន្លឹះ | 26,090,000.00 | ខែ ធ្នូ ឆ្នាំ ២០២៤ | |
| | សរុប | 80,000,000.00 | | |

ថ្ងៃ [illegible] ១២កើត ខែមាឃ ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ ២០២៤

ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ

មន្ទីរសុខាភិបាល រាជធានីភ្នំពេញ

**បណ្ឌិត ឌី មានហេង**

២.ការគ្របដណ្តប់សេវាបង្កាលើប្រជាជនគន្លឹះបានត្រឹម ៥៤%

-ការប៉ាន់ស្មានប្រជាជនគន្លឹះឆ្នាំ២០២៣ - ២០២៤ មាន ៥៥៦៧៥ នាក់។

៣.អត្រាជំងឺកាមរោគក្នុងចំណោមប្រជាជនគន្លឹះកើនឡើង។

៤.អត្រាប្រើប្រាស់ស្រោមអនាម័យបានត្រឹមតែ ៥៩%។

៥.ចំនួនករណីប្រើប្រាស់ PREP ១២៧១៧នាក់ (EW=១៨៥៩, MSM=៨៦៧៥, TG=១៦៣២, GP+ Partner ៥៤៦, PWID = ៥)។

៦.ចំនួនអ្នកផ្ទុកមេរោគអេដស៍ដែលទទួលបានបណ្តុំសមធម៌ ១៦,៨២២នាក់។

៧.ថវិកាអភិវឌ្ឍន៍សង្កាត់ សម្រាប់ឆ្លើយតបនឹងមេរោគអេដស៍ បានចំនួន ៥៥សង្កាត់ ស្មើនឹង ១៩៨,៦០០,០០០៛ ឆ្នាំ២០២៤។

៨.ចំនួនកិច្ចប្រជុំនានាទាក់ទងនឹងការប្រយុទ្ធនឹងជំងឺអេដស៍ ២៨ដង។

## ❖ ឱកាសភាពបរិយាកាសអំណោយផល

-ការចូលរួមរបស់អាជ្ញាធរក្នុងការគាំទ្រសកម្មភាព និងគាំទ្រផ្សេងៗមានលក្ខណៈល្អប្រសើរ។

-ការចូលរួមរបស់សហគមន៍ និងប្រជាជនគន្លឹះ ស្ត្រីធ្វើការតាមសេវាកំសាន្តសប្បាយ ក្រុមបុរសរួមភេទជាមួយបុរស (MSM) ក្រុមបំលែងភេទ (ប្រុសតែងខ្លួនជាស្រី) ក្រុមប្រើប្រាស់គ្រឿងញៀន និងអ្នករស់នៅជាមួយមេរោគអេដស៍មានការចូលរួមលើកិច្ចប្រជុំ និងព្រឹត្តិការណ៍ផ្សេងៗ។

## ៣- បញ្ហាប្រឈម

-ភាពខុសគ្នារវាងការប៉ាន់ស្មាន និងការអនុវត្តជាក់ស្តែង

-ការប្រឈមលើបទអន្តរាគមន៍

-ក្រុមការងារលេខាធិការដ្ឋានអេដស៍ចុះបំពេញភារកិច្ចពុំមានឳកាសម្រាប់ចំណាយលើបេសកកម្ម

-បុគ្គលិកតិច ការងារច្រើន

-ពេលខ្លះដាច់ស្តុក តេស្ត (Test)

-កង្វះស្រោមអនាម័យ និងទឹករំអិល

-កង្វះម្ជុលសឺរ៉ាំងសម្រាប់ក្រុម PWID

-ទាក់ទងនឹងការបង្ការ មានសកម្មភាពថយចុះ និងការគ្រប់ដណ្តប់ខ្វះចន្លោះច្រើន បច្ចុប្បន្នគ្របដណ្តប់បាន៥៤%។

## ❖ ទិសដៅឆ្នាំ២០២៤-២០២៥

-គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ បន្តការឆ្លើយតបទៅនឹងគោលដៅ ៩៥ទី១ ចំនួន ៥% ទៀត (បច្ចុប្បន្ន ៩៥ ទី១ ទទួលបាន ៩០%)។

-បន្តគ្រប់គ្រងអ្នកជំងឺអេដស៍មានស្រាប់ ប្រកបដោយសុខភាពល្អតាមរយៈការលេបថ្នាំត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់មួយជីវិត (ARV)។

-បានរៀបចំធ្វើផែនការសកម្មភាព និងថវិកា (FTCI) សម្រាប់ឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ ឆ្នាំ២០២៤ និងឆ្នាំ២០២៥។

-ពង្រឹងការធ្វើតេស្តឈាមចុងម្រាមដៃ និងការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង (HIVST)។

-សហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងគម្រោង LHSS ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍សង្កាត់ ពីតួនាទី ភារកិច្ច ក្នុងការចូលរួមទប់ស្កាត់ការរាលដាលមេរោគអេដស៍ ជំងឺអេដស៍ និងការធ្វើផែនការសកម្មភាពផែនការថវិកាចូលក្នុងផែនការវិនិយោគសង្កាត់ប្រចាំឆ្នាំ២០២៥-២០២៧។

-សហការជាមួយមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ រៀបចំធ្វើសិក្ខាសាលាផ្សព្វផ្សាយដល់នាយក នាយិកា តាមសាលាពីមេរោគអេដស៍ ជំងឺអេដស៍ ដល់សិស្សអនុវិទ្យាល័យ និងវិទ្យាល័យតាមសាលាមួយចំនួន។

-សហការជាមួយមន្ទីរទេសចរណ៍រាជធានីភ្នំពេញ ដើម្បីស្រង់ទិន្នន័យចំនួនសេវាកំសាន្តក្នុងរាជធានីភ្នំពេញ។

-បង្កើតសេវាបន្ថែម និងពង្រឹងបច្ចេកទេសជាបន្តបន្ទាប់ ដល់ក្រុមការងារថែទាំ ព្យាបាលមេរោគអេដស៍ ជំងឺអេដស៍តាមសេវាដែលមានស្រាប់។

-រៀបចំព្រឹត្តិការណ៍ជួបជុំជាមួយអង្គការដៃគូ និងប្រជាជនគន្លឹះ អ្នកផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ ដើម្បីស្វែងយល់បន្ថែមពីមធ្យោបាយបង្ការនានា។

-បន្តការរៀបចំឲ្យអ្នកជំងឺអេដស៍មានបណ្ណសមធម៌ ដែលបានដំណើរការពីខែមករា ឆ្នាំ២០២៣ និងដំណើរការបន្ត។

❖ **សំណូមពរ**

សូមឱ្យមានថវិកាសម្រាប់ដំណើរការប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមបណ្តាខណ្ឌ។

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២៤

**ប្រធានលេខាធិការដ្ឋានអេដស៍រាជធានីភ្នំពេញ**

**អនុប្រធានអចិន្ត្រៃយ៍**

**វេជ្ជបណ្ឌិត ឡុង ឡាវី**

# រូបភាព

## -យន្តការឆ្លើយតប



# អារម្ភកថា

ទោះបីជាប្រទេសកម្ពុជាមានការរីកចម្រើនខ្លាំងក្នុងការគ្រប់គ្រងការរីករាលដាលមេរោគអេដស៍ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកក៏ដោយ ក៏បញ្ហាប្រឈមសំខាន់ៗនៅតែមានចំពោះការសម្រេចបានគោលដៅចុងក្រោយ ដើម្បីឈានឆ្ពោះទៅបញ្ចប់ជំងឺអេដស៍ដែលជាការគំរាមកំហែងមួយចំពោះសុខភាពសាធារណៈជាពិសេសនៅរាជធានីភ្នំពេញ ដែលជាទីប្រជុំជនមានប្រជាជនរស់នៅច្រើនកុះករ សម្បូរទៅដោយទីតាំងសប្បាយភាព និងមានសេរីភាពទូលំទូលាយ ដែលជាហេតុធ្វើឱ្យទទួលរងនូវហានិភ័យចំពោះការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ហើយត្រូវទាមទារឱ្យមានការចូលរួមបង្ការទប់ស្កាត់ និងឆ្លើយតបបានទាន់ពេលវេលា។

ការព្រួយបារម្ភពីការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ជាការព្រួយបារម្ភរួមគ្នាទាំងថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ក៏ដូចជាថ្នាក់តំបន់ និងពិភពលោកទាំងមូល រហូតបានដាក់ចេញនូវគោលនយោបាយ និងគំនិតផ្តួចផ្តើមនានាធ្វើយ៉ាងណាជំរុញល្បឿនការបញ្ចប់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍។ ជាមួយគ្នានេះ គំនិតផ្តួចផ្តើមពន្លឿនការឆ្លើយតបការរីករាលដាលមេរោគអេដស៍នៅតាមទីក្រុង (Fast-Track Cities) ត្រូវបានឯកភាពគ្នាជាសាកលដើម្បីឆ្ពោះទៅបញ្ចប់ករណីឆ្លងថ្មី គ្មានការរើសអើង និងគ្មានការស្លាប់ដោយសារជំងឺអេដស៍ ហើយគំនិតផ្តួចផ្តើមនេះក៏ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ ការផ្ទេរអំណាចកាន់តែច្រើន និងការសម្រេចចិត្តទាក់ទងនឹងការអនុវត្តសកម្មភាពនានាពីអាជ្ញាធរថ្នាក់កណ្តាលទៅថ្នាក់រាជធានី ខេត្ត និងឃុំ/សង្កាត់។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ "ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព" របស់រាជរដ្ឋាភិបាលកម្ពុជាបានគូសបញ្ជាក់យ៉ាងច្បាស់អំពីគោលបំណងអភិវឌ្ឍប្រទេសដោយកំណត់យកអភិបាលកិច្ចល្អជាស្នូល និងផ្តល់អាទិភាពលើការអភិវឌ្ឍធនធានមនុស្ស ពិពិធកម្មសេដ្ឋកិច្ច ការងារក្នុងវិស័យឯកជន និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ននិងចីរភាព។

ផ្តើមចេញពីគំនិតផ្តួចផ្តើមជាសាកលខាងលើនេះផែនការយុទ្ធសាស្ត្រពន្លឿនការបញ្ចប់ការរីករាលដាលមេរោគអេដស៍នៅរាជធានីភ្នំពេញក៏ត្រូវបានរៀបចំឡើង ហើយក៏ជាយុទ្ធសាស្ត្រទី២ នៅកម្រិតរាជធានី/ខេត្ត ដែលបានរៀបចំឡើងនៅក្នុងប្រទេសកម្ពុជា និងមានគោលការណ៍យុទ្ធសាស្ត្រ Fast-Track គឺស្របតាមអាទិភាព និងគោលដៅកំណត់ដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ជាពិសេសគោលដៅ ៩៥-៩៥-៩៥ នឹងបញ្ចប់ការរីករាលដាលនៃជំងឺអេដស៍នៅត្រឹមឆ្នាំ ២០២៥។ គោលដៅ និងអាទិភាពទាំងនេះ ត្រូវបានយកមកគិតគូរ និងសម្របទៅនឹងស្ថានភាពជាក់ស្តែងរបស់រាជធានីភ្នំពេញ និងត្រូវបានផ្តោតការយកចិត្តទុកដាក់ជាពិសេស និងផ្អែកលើធាតុចូលដែលផ្តល់ដោយភាគីពាក់ព័ន្ធ ដូច្នេះផែនការយុទ្ធសាស្ត្រនេះគួរតែត្រូវបានចាត់ទុកជាវិធីសាស្ត្រត្រួសត្រាយផ្លូវដំបូងប៉ុណ្ណោះ ខណៈដែលការឆ្លើយតបនឹងមេរោគអេដស៍កម្រិតរាជធានី/ខេត្ត ឬក្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែផ្អែកលើអភិក្រមស្រាវជ្រាវតាមបរិបទជាក់ស្តែងរបស់រាជធានី ខេត្ត ឬក្រុងរបស់ខ្លួន។

ផែនការយុទ្ធសាស្ត្រនេះនឹងក្លាយជាមគ្គុទ្ទេសក៍ ដ៏មានប្រយោជន៍សម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងរាជធានីភ្នំពេញ ដើម្បីរួមចំណែកក្នុងការសម្រេចបានគោលដៅឆ្លើយតបនឹងមេរោគអេដស៍ថ្នាក់ជាតិ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះ ចំពោះកម្មវិធីរួមរបស់អង្គការសហប្រជាជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ (UN-AIDS) សម្រាប់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់ខ្លួន ក្នុងការអភិវឌ្ឍផែនការយុទ្ធសាស្ត្រដ៏មានសារសំខាន់នេះ។

ថ្ងៃ សុក្រ ៩កើត ខែ ស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០២៣

**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងជាប្រធាន**
**គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ**

**ឃួង ស្រេង**

## ឧបសម្ព័ន្ធទី ២៖ សមាជិកភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ និងលេខាធិការដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ:០៥៥/២៣ សសរ.ភ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ**
**និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខណ្ឌទាំង ១៤**

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យោងលិខិតលេខ ២២២/២៣ រប.ស.ណ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ របស់មន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានីភ្នំពេញ
- យោងភារកិច្ចចាំបាច់ចំពោះមុខ

**សម្រេច**

**ប្រការ ១ .-**

ត្រូវបានបង្កើត**គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ** ហៅកាត់ថា **គ.ប.ជ.អ. រាជធានីភ្នំពេញ** ដែលមានសមាសភាពដូចតទៅ៖

- រៀបចំរបាយការណ៍លទ្ធផលការងារ រួចផ្ញើមកលេខាធិការដ្ឋានរបស់ គ.ប.ជ.អ. រាជធានីភ្នំពេញ ឱ្យបានទៀងទាត់ និងទាន់ពេលវេលាកំណត់
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាំបាច់ ឬ តាមការប្រគល់ជូនពី គ.ប.ជ.អ. រាជធានីភ្នំពេញ។

**ប្រការ ៦ .-**

- គ.ប.ជ.អ. រាជធានីភ្នំពេញ មានសិទ្ធិប្រើប្រាស់ត្រារដ្ឋបាលរាជធានីភ្នំពេញ ដើម្បីអនុវត្តការងារ
- គ.ប.ជ.អ. ខណ្ឌ មានសិទ្ធិប្រើប្រាស់ត្រារដ្ឋបាលខណ្ឌសាមី ដើម្បីអនុវត្តការងារ
- លេខាធិការដ្ឋាន គ.ប.ជ.អ. រាជធានីភ្នំពេញ មានសិទ្ធិប្រើប្រាស់ត្រាមន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីអនុវត្តការងារ និងមានទីតាំងអចិន្ត្រៃយ៍ស្ថិតនៅមន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានីភ្នំពេញ
- គ.ប.ជ.អ. រាជធានីភ្នំពេញ និង គ.ប.ជ.អ. ខណ្ឌ និងលេខាធិការដ្ឋាន គ.ប.ជ.អ. រាជធានីភ្នំពេញ មានរបបប្រជុំជាទៀងរាល់ ០៣ខែម្តង ឬ តាមតម្រូវការចាំបាច់ជាក់ស្តែង ហើយលេខាធិការដ្ឋានជាសេនាធិការលើការរៀបចំកិច្ចប្រជុំនេះ
- សមាជិក-សមាជិកាដែលមានឈ្មោះក្នុងប្រការ ១ ប្រការ ៣ និងប្រការ ៤ ខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទ ដើម្បីអនុវត្តការងារ។ ក្នុងករណីសមាសភាពណាមួយដូចក្នុងប្រការ ១ ប្រការ ៣ និងប្រការ ៤ ខាងលើ បានផ្លាស់ប្តូរតួនាទី-ភារកិច្ច នោះសមាសភាពដែលត្រូវតែងតាំងមុខតំណែងថ្មីជំនួស ត្រូវទទួលអនុវត្តភារកិច្ចនេះបន្តពីសមាសភាពដែលបានផ្លាស់ចេញ
- គ.ប.ជ.អ. រាជធានីភ្នំពេញ និង គ.ប.ជ.អ. ខណ្ឌ និងលេខាធិការដ្ឋាន គ.ប.ជ.អ. រាជធានីភ្នំពេញ អាចធ្វើការកែសម្រួលសមាសភាព និងភារកិច្ចរបស់ខ្លួនតាមតម្រូវការចាំបាច់ ឬ តាមទំហំការងារជាក់ស្តែង។ ការកែសម្រួលសមាសភាព និងភារកិច្ច ត្រូវកំណត់ដោយសេចក្តីសម្រេចដែលចុះហត្ថលេខាដោយអភិបាលរាជធានីភ្នំពេញ តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន គ.ប.ជ.អ. រាជធានីភ្នំពេញ។

**ប្រការ ៧ .-**

សេចក្តីសម្រេចលេខ ៣៦១/២០ សសរ.អ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខណ្ឌទាំង ១៤ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨ .-**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង ១៤ ប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ ១ ប្រការ ៣ និងប្រការ ៤ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហ ៤រោជ ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣
**អភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
  "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៨
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# -ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២៣













Vital


NATIONAL AIDS AUTHORITY
ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូឆ្នាំ២០២២




ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍
ធ្វើឱ្យមានសមភាព ដើម្បីឆ្ពោះទៅរក
ការបញ្ចប់ការរាតត្បាតមេរោគអេដស៍ឆ្នាំ២០២៥
M.STYLE
មិត្តសំឡាញ់
mith samlanh
friends
international
ChildSafe
MOVEMENT
TOGETHER, PROTECTING CHILDREN

# -សិក្ខាសាលាពិគ្រោះយោបល់តម្រង់ទិសរបស់ FTCI






អរគុណសន្តិភាព!




This PC
New Volume (D:)
NAA
DFAT UNAIDS
Sort
View
Downloads
Documents
Ending Financal Reort 30-05-2023.pdf
DFAT_Activties_Table_05052023.docx





# -សិក្ខាសាលាគណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ និងគណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍ទាំង១៤ខណ្ឌ












# -វគ្គបណ្តុះបណ្តាលដល់គណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍សង្កាត់ ស្តីពី ការដាក់បញ្ចូលកម្មវិធីអេដស៍ក្នុងផែនការវិនិយោគសង្កាត់ និងតួនាទីរបស់គណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍សង្កាត់ឆ្នាំ២០២៣








SUNWAY HOTEL
PHNOM PENH
“តួនាទី
Roles and
HIV/AIDS Activities





ការសម្របសម្រួល
១.ការិយាល័យផែនការគាំទ្រ
សង្កាត់ របស់ក្រុង ឬខណ្ឌ
តើត្រូវរៀបចំផែនការសង្កាត់
ដើម្បីបានមូលនិធិសង្កាត់ ?

-វគ្គបណ្តុះបណ្តាលដល់គណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍សង្កាត់ ស្តីពី ការដាក់បញ្ចូលកម្មវិធីអេដស៍ក្នុងផែនការវិនិយោគសង្កាត់ និងតួនាទី របស់គណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍សង្កាត់ឆ្នាំ២០២៤








វគ្គបណ្ដុះបណ្ដាលស្ដីពី
USAID
SUNWAY HOTEL
PHNOM PENH


SUNWAY HOTEL
PHNOM PENH
USAID




SUNWAY HOTEL
PHNOM PENH


Training Workshop on Roles and Responsibilities of Commune/Sangkat AIDS


វគ្គបណ្តុះបណ្តាលស្តីពី
Training Workshop on Roles and Responsibilities of Comm
ngkat AIDS Committee (CAC) in planning and budgeting
to integrate HIV activities into the Commune/Sangka
ment-Investment Plan (HIVinCIP) in Phnom Penh
Sunway Hotel Phnom Penh,
October 17th-18th, 2024


EXIT




បទបង្ហាញ
ស្តីពី
ការពិនិត្យការដាក់បញ្ចូលសកម្មភាពអេដស៍ក្នុងកម្មវិធី
វិនិយោគបីឆ្នាំរំកិលសង្កាត់ រាជធានីភ្នំពេញ
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០២៤
SUNWAY HOTEL
PHNOM PENH


Training Workshop on Ro
to integrate HIV activ
VinCIP)
of Commune / Sangkat AIDS
Sangkat Development-Invest
Penh, Phnom Penh, October 17
g and budg
nom Penh
USAID

## -សិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨







B1-002


POLICE


B1-002











# -សិក្ខាសាលាលេខាធិការដ្ឋានអេដស៍រាជធានីភ្នំពេញ















-សិក្ខាសាលាសម្របសម្រួលជាមួយអង្គការដៃគូ






សាលា ស្ដីពីការសម្របសម្រួលជាមួយអង្គការដៃគូ
អនុវត្តសកម្មភាពប្រយុទ្ធ នឹងមេរោគអេដស៍/
ដស៍ក្នុងរាជធានីភ្នំពេញ
ភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០២៤

